01324732

E424/1

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 02 / 09 / 2016
ម៉ោង (Time/Heure) : 15:15
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១៦

**ជូនចំពោះ៖** **ភាគីទាំងអស់នៃសំណុំរឿង ០០២**

**ពី៖** **ចៅក្រម យ៉ា សុខន ជ.ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន៖** **លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ៖** **សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី នួន ជា តាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង ទាក់ទងនឹងសាក្សីដែលមានរហស្សនាម 2-TCW-1005**

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើសុំមួយដែលបានដាក់ជាសម្ងាត់ដោយក្រុមមេធាវីការពារក្តី នួន ជា កាលពីថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១៦ (ឯកសារ E424) ដែលក្នុងសំណើនោះ មេធាវីការពារក្តីសុំឱ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីក្នុងសំណុំរឿង ០០៣ ("ឯកសារ") ជាប់ពាក់ព័ន្ធជាមួយសាក្សី 2-TCW-1005 ដែលគ្រោងនឹងមកផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះ ("សំណើ")។ ដោយបានស្តាប់សារណាផ្ទាល់មាត់លើសំណើសុំ កាលពីថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៦ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចផ្ទាល់មាត់ក្នុងថ្ងៃដដែលនោះ ដោយសំអាងហេតុជាលាយលក្ខណ៍អក្សរនឹងចេញជូនតាមក្រោយ។ សេចក្តីសម្រេចនោះបានអនុញ្ញាតតាមសំណើសុំ ហើយទទួលយកឯកសារ E319/43.3.3 ធ្វើជាឯកសារភស្តុតាង ដោយដាក់លេខសម្គាល់ E3/10639។ ហេតុដូច្នេះ អង្គជំនុំជម្រះសូមផ្តល់នូវសំអាងហេតុ សម្រាប់សេចក្តីសម្រេចរបស់ខ្លួន ដូចខាងក្រោម។

២. មេធាវីការពារក្តី នួន ជា បានលើកឡើងថា កំណត់ហេតុស្តាប់ចម្លើយចំនួនពីរ របស់សាក្សីក្នុងសំណុំរឿង ០០៣ រូបនេះ ត្រូវបានអង្គជំនុំជម្រះសាលាដំបូងទទួលយករួចហើយ កាលពីខែមិថុនា ឆ្នាំ ២០១៦ (ឯកសារ E319/47/3.1) ហើយដើម្បីជាប្រយោជន៍យុត្តិធម៌ គួរតែមានការវាយតម្លៃទៅលើប្រភពរួមគ្នា។ មេធាវីការពារក្តីបានលើកឡើងថា ជាបឋម ឯកសារមានភាពអាចជឿជាក់បាន មានភាពពាក់ព័ន្ធ និង មិនច្រំដែល ដោយសារឯកសារមានព័ត៌មានបន្ថែមដែលមិនធ្លាប់មាននៅក្នុងកំណត់ត្រាភ័ស្តុតាងដែលអង្គជំនុំជម្រះបានទទួលយកកន្លងមក (ឯកសារ E424 កថាខណ្ឌ ១, ៨ ដល់១៤)។ មេធាវីការពារក្តី នួន ជា បានកត់សម្គាល់ថាឯកសារត្រូវបានដាក់បង្ហាញកាលពីថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៦ ដូច្នេះ ឯកសារនេះមិនអាចរកបាននៅមុនពេលបើកសវនាការឡើយ (ឯកសារ E424 កថាខណ្ឌ ១០)។

៣. នៅក្នុងសារណាផ្ទាល់មាត់កាលពីថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៦ មេធាវីការពារក្តី ខៀវ សំផន បើទោះបីជាមិនជំទាស់ទៅនឹងសំណើសុំ តែបានកត់សម្គាល់ថាក្នុងពេលកន្លងមក អង្គជំនុំជម្រះសាលាដំបូងបានបដិសេធទៅលើសំណើសុំមួយរបស់សហព្រះរាជអាជ្ញាអន្តរជាតិសូមឱ្យទទួលយកឯកសារដដែលនេះ (សូមមើលប្រតិចារឹកថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៦, ទំព័រ ៧ ដល់ ៨ (សេចក្តីព្រាង) ឯកសារ E319/47/3 ជើងទំព័រ ៣៨)។ មិនមានភាគីដទៃបានលើកឡើងនូវសារណាផ្ទាល់មាត់ ជាចម្លើយតបនោះឡើយ។

៤. យោងតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូង ក្នុងកំឡុងពេលសវនាការអាចទទួលយកនូវភ័ស្តុតាងថ្មី ដែលមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត ក្នុងករណីដែលភ័ស្តុតាងនោះបំពេញបានតាមបទដ្ឋានបឋម នៃភាពពាក់ព័ន្ធ ភាពអាចជឿជាក់បាន និង យថាភាព ដូចដែលតម្រូវដោយវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះសម្រេចទៅលើខ្លឹមសារនៃសំណើសុំឱ្យទទួលយកភ័ស្តុតាងថ្មី ផ្អែកតាមលក្ខណៈវិនិច្ឆ័យ ក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។ វិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងក៏តម្រូវផងដែរថា ភាគីណាមួយដែលបានស្នើសុំឱ្យទទួលយកភ័ស្តុតាងថ្មី ត្រូវស្នើឡើងតាមសារណាដោយមានសំអាងហេតុ។ ភាគីស្នើសុំត្រូវធ្វើឱ្យអង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា ភ័ស្តុតាងដែលបានស្នើសុំ មិនអាចរកបាននៅមុនពេលបើកសវនាការ ឬ មិនអាចរកឃើញទោះជាមានការប្រឹងប្រែងសមស្របក៏ដោយ។ ទោះជាយ៉ាងនេះក្តី នៅក្នុងករណីមួយចំនួន អង្គជំនុំជម្រះអាចទទួលយកភ័ស្តុតាងដែលមិនបានបំពេញពេញលេញតាមលក្ខណៈវិនិច្ឆ័យនេះ ដោយរួមទាំងករណីដែលភ័ស្តុតាងទាក់ទងជិតស្និទជាមួយសម្ភារៈដែលមានស្រាប់ នៅចំពោះមុខអង្គជំនុំជម្រះ និង ក្នុងករណីដែល

ប្រយោជន៍យុត្តិធម៌តម្រូវឱ្យធ្វើការវាយតម្លៃរួមគ្នា ទៅលើប្រភព និង ក្នុងករណីដែលភ័ស្តុតាងនោះ ជាភ័ស្តុតាងដោះបន្ទុក ហើយតម្រូវឱ្យមានការវាយតម្លៃ ដើម្បីជៀសវាងកំហុសក្នុងការស្វែងរកយុត្តិធម៌ (សូមមើលឯកសារ E319/36/2)។

៥. អង្គជំនុំជម្រះកត់សម្គាល់ថា ខ្លួនបានបដិសេធសំណើកន្លងមក ដែលសុំឱ្យទទួលយកឯកសារដោយសារតែមូលដ្ឋាននីតិវិធី ព្រោះសហព្រះរាជអាជ្ញាអន្តរជាតិ មិនបានគោរពទៅតាមគោលការណ៍ណែនាំរបស់អង្គជំនុំជម្រះទាក់ទងសំណើសុំតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង (ឯកសារ E319/47/3 ជើងទំព័រ ៣៨ យោងទៅរកឯកសារ E363/3 កថាខណ្ឌ ៣៦)។ ផ្ទុយទៅវិញមេធាវីការពារក្តីមិនជាប់កាតព្វកិច្ចបែបនេះឡើយ។ ហេតុដូច្នេះ ទើបអង្គជំនុំជម្រះពិចារណាទៅលើខ្លឹមសារនៃសំណើសុំនេះ។

៦. អង្គជំនុំជម្រះកត់សម្គាល់ថា ឯកសារត្រូវបានដាក់បង្ហាញដល់មេធាវីការពារក្តី កាលពីថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៦ ដូច្នេះហើយមេធាវីការពារក្តី នួន ជា មិនអាចរកបានឯកសារនេះ នៅមុនពេលបើកសវនាការឡើយ។ ប៉ុន្តែ បើទោះបីជាភាគីត្រូវបានជូនដំណឹងកាលពីថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៦ អំពីការជ្រើសរើស 2-TCW-1005 ធ្វើជាសាក្សី សំណើទើបត្រូវបានធ្វើឡើងនៅថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១៦ គឺជិតបួនខែក្រោយ ហើយនៅជិតដល់ពេលផ្តល់សក្ខីកម្មរបស់សាក្សី 2-TCW-1005។ អង្គជំនុំជម្រះសូមរំឭកដល់ភាគីថា សំណើតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង គួរត្រូវបានដាក់ភ្លាមៗ ហើយបានកត់សម្គាល់ថា មេធាវីការពារក្តី នួន ជាអាចដាក់ ហើយគួរដាក់សំណើនេះឱ្យបានឆាប់ជាងនេះ។ ទោះជាយ៉ាងនេះក្តី ដោយពិចារណាទៅលើសារណារបស់ភាគី និង ដោយកត់សម្គាល់ថាកំណត់ហេតុស្តាប់ចម្លើយពីរទៀតរបស់បុគ្គលរូបនេះត្រូវបានទទួលយកធ្វើជាឯកសារភ័ស្តុតាងរួចហើយនោះ អង្គជំនុំជម្រះសម្រេចថា ឯកសារដែលបានស្នើសុំពាក់ព័ន្ធជិតស្និទ្ធ ជាមួយសម្ភារៈដែលមានរួចហើយ នៅចំពោះមុខអង្គជំនុំជម្រះ ហើយសម្រេចថាដើម្បីប្រយោជន៍យុត្តិធម៌ ត្រូវទទួលយកផងដែរនូវកំណត់ហេតុស្តាប់ចម្លើយទីបី (ឯកសារ E319/43.3.3) ដើម្បីស្វែងរកការពិត។

៧. អនុស្សរណៈនេះគឺជាចម្លើយតបផ្លូវការរបស់អង្គជំនុំជម្រះចំពោះឯកសារ E424។